01563220

លេខ៖ D378

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
Office of the Co-Investigating Judges
Bureau des co-juges d'instruction

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 01-Mar-2018, 10:37
CMS/CFO: Sann Rada

សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ ៖ ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៨

ភាសា ៖ ខ្មែរ & អង់គ្លេស

ចំណាត់ថ្នាក់ឯកសារ ៖ សាធារណៈ/Public

# ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យយោងតាមវិធានផ្ទៃក្នុង ៦៦(៤)

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី យឹម ទិត្យ**

សូ មូស្សេរ្នី
Suzana TOMANOVIĆ
Neville SORAB

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីនែ
ទី ស្រីនណា
វ៉េន ពៅ

Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARTI

១. ករណីខ្វែងយោបល់រវាងសហចៅក្រមស៊ើបអង្កេត (“ស.ច.ស”) នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ និងថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧។

២. នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិ (“ស.ព.អ”) បានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ដោយចោទថា យឹម ទិត្យ ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក[1]។ ដោយសារថាមានករណីខ្វែងយោបល់រវាងសហព្រះរាអាជ្ញា ទើប ស.ព.អ ស្ដីទី បានបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ជូន ស.ច.ស នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩[2]។ បន្ទាប់មក ស.ព.អ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដោយចោទថា យឹម ទិត្យ ទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មបន្ថែមទៀត[3]។

៣. នៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ ស.ច.ស.អ បានដាក់ យឹម ទិត្យ ឱ្យស្ថិតក្រោមការពិនិត្យពីបទរំលោភលើមាត្រា ៥០១ និង៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ (មនុស្សឃាតគិតទុកជាមុន) អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩[4]។ នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧

---

[1]សំណុំរឿង ០០៤ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨។

[2]សំណុំរឿង ០០៤ ឯកសារ D1/1 *សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទីអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣* ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩។

[3]សំណុំរឿង ០០៤ ឯកសារ D65 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១។ សំណុំរឿង ០០៤ ឯកសារ D191 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬយេនឌ័រ* ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤។ សំណុំរឿង ០០៤ ឯកសារ D254/1 *ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវត្តតាមះ* ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៥។ សំណុំរឿង ០០៤ ឯកសារ D272/1 *ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរលើអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់ ១ និងតំបន់ ៤* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥។

[4]សំណុំរឿង ០០៤ ឯកសារ D281 *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង* ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥។

ស.ច.ស.អ បានចេញដីកាសម្រេចកែប្រែបទចោទដើម្បីបញ្ចូលទម្រង់នៃការទទួលខុសត្រូវបន្ថែមទៀត[5]។

៤. នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧ ស.ច.ស.អ បានចេញដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ យោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន*[6]។

៥. នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧ យើងបានជូនដំណឹងភាគី អំពីការបិទកិច្ចស៊ើបសួរលើ យឹម ទិត្យ ហើយបានជូនដំណឹងថា ភាគីមានរយៈពេល ១៥ ថ្ងៃចាប់ពីពេលជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ ដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែម[7]។

៦. នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៧ មេធាវីការពារក្តី បានដាក់សំណើសុំពន្យារពេលរយៈពេល ១៥ ថ្ងៃនេះឱ្យបានយ៉ាងហោចណាស់ប្រាំមួយខែ (“សំណើសុំពន្យារពេល”)[8]។

៧. នៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៧ ស.ព.អ បានដាក់សំណើសុំការបញ្ជាក់អំពីដីកាសម្រេចរបស់ ស.ច.ស.អ លើសំណើរបស់ ស.ព.អ សុំបំពេញកិច្ចស៊ើបសួរទាក់ទងនឹងរបាយការណ៍វិភាគរបស់ [redacted] (“សំណើសុំការបញ្ជាក់”)[9]។

៨. នៅថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៧ យើងបានចេញដីកាសម្រេចលើសំណើសុំពន្យារពេលដោយបដិសេធសំណើសុំពន្យារពេលរយៈពេលប្រាំមួយខែ ប៉ុន្តែ បានអនុញ្ញាតផ្តល់ជូនភាគីនូវ

---

[5]សំណុំរឿង 00៤ ឯកសារ D350 *ដីកាសម្រេចកែប្រែបទចោទប្រឆាំង យឹម ទិត្យ* ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧។ សំណុំរឿង 00៤ ឯកសារ D350.1 *ឧបសម្ព័ន្ធ៖ សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យឹម ទិត្យ ដែលបានកែប្រែ* ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧។

[6]សំណុំរឿង 00៤ ឯកសារ D359 *ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ យោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន* ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧។

[7]សំណុំរឿង 00៤ ឯកសារ D358 *សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរលើយឹម ទិត្យ* ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧។

[redacted]

រយៈពេល ៣០ ថ្ងៃបន្ថែមវិញ គឺរហូតដល់ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៧ អាចស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែមបាន(“ដីកាសម្រេចលើសំណើសុំពន្យារពេល”)[10]។

៩. នៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៧ និងថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៧ ស.ព.អ បានដាក់សំណើសុំដាក់ឯកសារមួយចំនួនចូលក្នុងសំណុំរឿង ០០៤[11]។ ស.ច.ស.អ បានចេញដីកាសម្រេចលើសំណើទាំងនោះ នៅថ្ងៃទី២៥ ខែកក្កដា និងថ្ងៃទី១៥ ខែ សីហា ឆ្នាំ២០១៧[12]។

១០. នៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៧ មេធាវីការពារក្តី បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំពន្យារពេល (“បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី”)[13]។

១១. នៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៧ ស.ព.អ បានដាក់សំណើចំនួនពីរស្នើសុំបំពេញកិច្ចស៊ើបសួរ៖ សំណើទីមួយ ស្នើសុំបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងគុកលេខ ៨ នៅស្រុកកណ្តៀង និងអំពើហិង្សាផ្លូវភេទនៅស្រុកបាកាន (“សំណើសុំបំពេញកិច្ចស៊ើបសួរទីមួយរបស់ ស.ព.អ”)[14]

---

[redacted]

[14]សំណុំរឿង ០០៤ D365 *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងគុកលេខ ៨ នៅស្រុកកណ្តៀង និងអំពើហិង្សាផ្លូវភេទនៅស្រុកបាកាន ខេត្តពោធិ៍សាត់* ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៧។

និងសំណើទីពីរ ស្នើសុំបំពេញកិច្ចស៊ើបសួរដូចបានបង្ហាញនៅក្នុងឧបសម្ព័ន្ធដែលបានភ្ជាប់ជាមួយសំណើ("សំណើសុំបំពេញកិច្ចស៊ើបសួរទីពីរ របស់ ស.ព.អ")[15]។

១២. នៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៧ មេធាវីការពារក្តី បានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងការប្រើប្រាស់[redacted]ដែលទទួលបានដោយសារការធ្វើទារុណកម្ម ("សំណើសុំបំពេញកិច្ចស៊ើបសួររបស់មេធាវីការពារក្តី")[16]។

១៣. នៅថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៧ ស.ច.ស.អ បានចេញដីកាសម្រេចផ្នែកខ្លះលើសំណើសុំបំពេញកិច្ចស៊ើបសួរទីពីរ របស់ ស.ព.អ[17]។

១៤. នៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៧ ស.ច.ស.អ បានចេញដីកាសម្រេចលើសំណើសុំការបញ្ជាក់[18]។

១៥. នៅថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៧ ស.ច.ស.អ បានចេញដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរទីមួយ របស់ ស.ព.អ និងលើផ្នែកសេសសល់ផ្សេងទៀតនៃសំណើសុំបំពេញកិច្ចស៊ើបសួរទីពីរ របស់ ស.ព.អ[19]។

១៦. នៅថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៧ ស.ច.ស.អន្តរជាតិ បានចេញដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់មេធាវីការពារក្តី[20]។

---

[redacted]

[19]សំណុំរឿង ០០៤ D365/3 *ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងគុកលេខ ៨ និងអំពើហិង្សាផ្លូវភេទនៅក្នុងស្រុកបាកាន* ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៧។ [redacted]

01563225



១៧. នៅថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៧ យើងបានចេញសេចក្តីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរ ហើយបានជូនដំណឹងភាគីថា មិនមានការផ្តល់ជូនពេលវេលាបន្ថែមទៀតដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរឡើយ[21]។

១៨. នៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៧ មេធាវីការពារក្តី បានដាក់ពាក្យសុំប្តឹងទៅ អង្គបុរេជំនុំជម្រះ ("អ.ប.ជ") ស្នើសុំមោឃភាពឯកសារមួយចំនួនទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី ("សំណើសុំមោឃភាពលើកទីមួយ")[22]។

១៩. នៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៧ ស.ច.ស.អ បានអនុញ្ញាតតាមសំណើសុំមោឃភាពទីមួយ ហើយបានបង្គាប់ឱ្យបញ្ជូនសំណុំរឿងជូនទៅ អ.ប.ជ ដើម្បីសម្រេចលើសំណើនេះ[23]។

២០. នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៧ ស.ព.អ បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ ស.ច.ស.អ លើសំណើសុំបំពេញកិច្ចស៊ើបសួរទីមួយ របស់ ស.ព.អ ("បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ")[24]។

២១. នៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៧ មេធាវីការពារក្តី បានដាក់ពាក្យសុំប្តឹងទៅ អ.ប.ជ ស្នើសុំមោឃភាពភស្តុតាងដែលទទួលបានដោយសារការធ្វើទារុណកម្ម("សំណើសុំមោឃភាពលើក

---

[redacted]

[21] សំណុំរឿង ០០៤ ឯកសារ D368 *សេចក្តីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរលើ យឹម ទិត្យ* ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៧។

[redacted]

ទីពីរ")[25]។ ស.ច.ស.អ បានចេញអនុស្សរណៈផ្ញើជូនភាគី ដោយជូនដំណឹងថា ស.ច.ស.អ មានបំណងរង់ចាំសេចក្តីសម្រេចពី អ.ប.ជ លើបញ្ហាចោទស្រដៀងគ្នានេះដែលកំពុងរង់ចាំសេចក្តីសម្រេចនៅក្នុងសំណុំរឿង 00៣ មុនពេល ស.ច.ស.អ សម្រេចថាតើត្រូវបញ្ជូនសំណើសុំមោឃភាពលើកទីពីរ ទៅ អ.ប.ជ ដែរឬអត់[26]។

២២. នៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៧ អ.ប.ជ បានចេញសេចក្តីសម្រេចបដិសេធបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី[27]។

២៣. នៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៨ ដោយសារថានៅត្រឹមដំណាក់កាលនោះ អ.ប.ជ មិនទាន់មានសេចក្តីសម្រេចលើបញ្ហាចោទស្រដៀងគ្នានៅក្នុងសំណុំរឿង 00៣ ដែលបានលើកឡើងនៅកថាខណ្ឌ ២១ ខាងលើ ទើប ស.ច.ស.អន្តរជាតិ បានអនុញ្ញាតតាមសំណើសុំមោឃភាពលើកទីពីរ ហើយបង្គាប់ឱ្យបញ្ជូនសំណុំរឿងជូនទៅ អ.ប.ជ ដើម្បីសម្រេចលើសំណើនេះ[28]។

២៤. នៅថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៨ មេធាវីការពារក្តី បានដាក់សំណើសុំកែតម្រូវកំហុសបកប្រែភាសានៅក្នុងកំណត់ហេតុស្តាប់ចម្លើយមួយចំនួននៅក្នុងសំណុំរឿង ("សំណើសុំកែតម្រូវរបស់មេធាវីការពារក្តី") [29]។

២៥. នៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៨ អ.ប.ជ បានចេញសាលដីកាបដិសេធបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ[30]។

---

[redacted]

២៦. នៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៨ ស.ច.ស.អ បានចេញដីកាសម្រេចលើសំណើសុំកែតម្រូវរបស់មេធាវីការពារក្តី និងបានណែនាំឲ្យអង្គភាពបកប្រែភាសា ធ្វើការកែតម្រូវទាំងអស់លើកំណត់ហេតុស្តាប់ចម្លើយដែលជាប់ពាក់ព័ន្ធ តាមការអនុញ្ញាតនៅក្នុងដីកាសម្រេចនោះ[31]។

២៧. គិតត្រឹមកាលបរិច្ឆេទនៃថ្ងៃចេញដីកាបញ្ជូនសំណុំរឿងទៅពិនិត្យនេះ អ.ប.ជ នៅតែពិនិត្យសំណើសុំមោឃភាពលើកទីមួយ និងលើកទីពីរ។ ប៉ុន្តែ ដោយសារថា ពាក្យសុំមោឃភាពទាំងនេះកំពុងរង់ចាំសេចក្តីសម្រេចនៅចំពោះមុខ អ.ប.ជ ទើបយើងយល់ឃើញថាមិនចាំបាច់ទាល់តែមានសេចក្តីសម្រេចលើពាក្យសុំទាំងនេះជាមុនសិនទេទើប ស.ព អាចដាក់ដីកាសន្និដ្ឋានស្ថាពរ យោងតាមវិធានផ្ទៃក្នុង ៦៦(៥) ឬក៏មេធាវីការពារក្តី អាចដាក់ចម្លើយតបបាន។ សំណើសុំមោឃភាពលើកទីមួយ និងលើកទីពីរ ពាក់ព័ន្ធនឹងប្រភេទភ័ស្តុតាងផ្សេងគ្នានៅក្នុងសំណុំរឿង។ ក្នុងករណីដែល អ.ប.ជ អនុញ្ញាតាមសំណើណាមួយក្នុងចំណោមសំណើទាំងនេះ ហើយនាំឱ្យមានផលប៉ះពាល់មកលើភ័ស្តុតាងនៅក្នុងសំណុំរឿង នោះ យើងនឹងចេញដីកាសម្រេចសមស្របក្នុងករណីចាំបាច់ដើម្បីបញ្ជូលផលប៉ះពាល់បែបនោះ ហើយផ្តល់ជូនភាគីនូវពេលវេលាបន្ថែមទៀតដើម្បីដាក់ដីកាសន្និដ្ឋានស្ថាពរ ឬចម្លើយតបក្នុងករណីចាំបាច់ ឬក៏ក្នុងករណីដែលដីកាសន្និដ្ឋានស្ថាពរឬចម្លើយតបបានដាក់រួចហើយ គឺអនុញ្ញាតផ្តល់ជូនពេលវេលាឱ្យធ្វើការកែសម្រួលវិញ។ នៅក្នុងបរិបទនៃការអនុវត្ត របស់យើង យើងសូមរំឭកភាគីទាំងអស់ថា ក្នុងករណីណាក៏ដោយ ក៏យើងនឹងមិនពឹងផ្អែកលើភ័ស្តុតាងដែលទទួលបានដោយសារការធ្វើទារុណកម្មឡើយ នៅពេលដែលយើងធ្វើសេចក្តីសន្និដ្ឋាននៅក្នុងដីកាដំណោះស្រាយ ដោយមិនគិតថា ភ័ស្តុតាងបែបនោះនៅតែមាននៅក្នុងសំណុំរឿង ឬត្រូវ អ.ប.ជ ដកចេញជាផ្លូវការនោះឡើយ ហើយភាគីទាំងអស់គួរចងចាំចំណុចនេះនៅពេលដែលរៀបចំសេចក្តីសន្និដ្ឋានរបស់ខ្លួន។

---

[30]សំណុំរឿង ០០៤ ឯកសារ D365/3/1/5 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរទាក់ទងអំពីហិង្សាផ្លូវភេទនៅគុកលេខ ៨ និងនៅក្នុងស្រុកបាកាន* ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៨។

[redacted]

01563228



២៨. យើងយល់ឃើញថា ដើម្បីជាប្រយោជន៍ដល់កិច្ចការរដ្ឋបាលតុលាការឱ្យបានត្រឹមត្រូវ ឥឡូវនេះ គឺត្រូវអញ្ជើញ ស.ព ឱ្យដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន។

២៩. យោងតាមវិធានផ្ទៃក្នុង ៦៦(៥) ស.ព មានរយៈពេល បី ខែ ចាប់ពីពេលចេញសេចក្តីជូនដំណឹងអំពីដីកានេះ ដើម្បីដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួនទាំងពីរភាសា។ ប៉ុន្តែ ការិយាល័យរបស់ ស.ព.អ បានជូនដំណឹងថា ការិយាល័យរបស់ ស.ព.អ ត្រូវការពេលវេលាបីខែពេញដើម្បីរៀបចំដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ តែជាភាសាអង់គ្លេសទេ[32]។ ស.ព.ជ មិនបានជូនដំណឹងបែបនេះឡើយ។

៣០. យោងតាមការអនុវត្តពីមុនមកនៅក្នុងសំណុំរឿង 00៣ និង 00៤/២ យើងទទួលយកការប៉ាន់ស្មានចំនួនពេលវេលារបស់ ស.ព.អ ហើយអនុញ្ញាតឱ្យគាត់ ដាក់ដីកាសន្និដ្ឋានស្ថាពរក្នុងរយៈពេលបីខែ ជាភាសាអង់គ្លេសសិន ចាប់ពីពេលជូនដំណឹងអំពីដីកានេះ បន្ទាប់មក ត្រូវដាក់សំណៅបកប្រែទាំងស្រុងជាភាសាខ្មែរឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។

៣១. នៅពេលដែលសំណៅបកប្រែទាំងស្រុងជាភាសាខ្មែរបានដាក់រួចភ្លាម មេធាវីការពារក្តី នឹងទទួលបានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើការឆ្លើយតប។ យើងនឹងបង្គាប់ឱ្យមេធាវីការពារក្តីផ្តល់ជូននូវការប៉ាន់ស្មានចំនួនពេលវេលាដែលមេធាវីការពារក្តី ត្រូវការដើម្បីដាក់ចម្លើយតបរបស់ខ្លួនជាភាសាអង់គ្លេស នៅពេលដែល ស.ព.អ បានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ជាភាសាអង់គ្លេស។

**តាមសំអាងហេតុខាងលើ យើង**[33]៖

៣២. **បញ្ជូន** សំណុំរឿង 00៤ ដែលស្ថិតក្រោមការស៊ើបសួរ ជូនទៅ ស.ព ក្នុងគោលបំណងដើម្បីចេញដីកាសន្និដ្ឋានស្ថាពរ យោងតាមវិធានផ្ទៃក្នុង ៦៦(៤)។

[redacted]

[33] សហចៅក្រមស៊ើបអង្កេតទាំងពីរ ចេញដីកានេះរួមគ្នា ប៉ុន្តែ ដើម្បីទុកជាកំណត់ហេតុ ស.ច.ស.ជ កត់សម្គាល់ថា ឯកសារនានាដាក់ចូលក្នុងសំណុំរឿង 00៤ គួរដាក់លេខរៀងបន្តពីឯកសារចុងក្រោយដែលបានដាក់ចូលក្នុងសំណុំរឿងមុនពេលការលាលែងតំណែងរបស់ចៅក្រម Siegfried Blunk ដោយមិនបញ្ចូលឯកសារដីកា និងដីកាសម្រេចដែលចេញដោយចៅក្រមបម្រុង Laurent Kasper-Ansermet ទេ។

៣៣. **អនុញ្ញាតឱ្យ** ស.ព ដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ជាភាសាអង់គ្លេសសិន ក្នុងរយៈពេលបីខែចាប់ពីពេលចេញសេចក្តីជូនដំណឹងអំពីដីកានេះ បន្ទាប់មក ត្រូវដាក់សំណៅបកប្រែទាំងស្រុងជាភាសាខ្មែរឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។

៣៤. **បន្ទាប់ឱ្យ** មេធាវីការពារក្តី ផ្តល់ជូនការប៉ាន់ស្មានចំនួនពេលវេលាដែលខ្លួនត្រូវការដើម្បីដាក់ចម្លើយតបជាភាសាអង់គ្លេស និងត្រូវផ្តល់ជូនការប៉ាន់ស្មាននេះក្នុងរយៈពេលមួយសប្តាហ៍ចាប់ពីពេលជូនដំណឹងអំពីសំណៅជាភាសាអង់គ្លេសនៃដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ។

រាជធានី ភ្នំពេញ ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៨

**សហចៅក្រមស៊ើបអង្កេត**

Co-Investigating Judges
Co-juge d'instruction

**យូ ប៊ុនឡេង** **Micahel BOHLANDER**